# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


Intervention request letter of FMR. Senator and KKC Executive Director Thach Setha to Cambodian Prime Minister Hun Sen on 08/06/07 for the return of Ven. Tim Sakhorn in Vietnam to Cambodia.

**គោរពជូន**

**សម្តេចហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា**

លេខ ០៣៣៥/០៧ ស.ខ.ក.ក.

**កម្មវត្ថុ:** សំណើសុំជួយអន្តរាគមន៍ទៅរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីនាំយកព្រះតេជគុណទឹម សាខន ត្រឡប់មកព្រះរាជាណាចក្រកម្ពុជា ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ព្រះតេជគុណទឹម សាខន ព្រះចៅអធិការវត្តភ្នំដិនខាងជើង ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ ត្រូវបានសង្ឃរាជាគណៈចាប់ផ្សឹកតាមលិខិតលេខ៩០២/០៧ស.ខ.ក.ជ. ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៧ របស់សម្តេចសង្ឃនាយកនួន ង៉ែត ដោយមានចំណារឯកភាពរបស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីទេព វង្ស ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៧ ដោយបានចោទប្រកាន់ថាបានធ្វើឱ្យបែកបាក់សាមគ្គីភាពកម្ពុជា-វៀតណាម ។ បន្ទាប់ពីបានចាប់ផ្សឹករួច នៅវេលាម៉ោង៣:៤០នាទីរសៀល ថ្ងៃ ខែ ឆ្នាំដដែល មានក្រុមអង្គរក្សមួយក្រុម(មិនស្គាល់អត្តសញ្ញាណ) បាននាំយកព្រះតេជគុណទឹម សាខនតាមរថយន្តចេញទៅបាត់របូតដោយពុំបានដឹងថា នាំយកព្រះអង្គទៅទីណាឡើយ ។ លុះដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ ទើបសហគមន៍ខ្មែរកម្ពុជាក្រោមបានដឹងតាមប្រព័ន្ធផ្សព្វផ្សាយរបស់វៀតណាមថា ព្រះតេជគុណទឹម សាខន ត្រូវបានអាជ្ញាធរប្រទេសវៀតណាមចាប់ឃុំខ្លួនក្នុងពន្ធនាគារប្រទេសវៀតណាម ដោយចោទប្រកាន់ពីបទ: ទី១ ឆ្លងដែនចូលប្រទេសវៀតណាមដោយខុសច្បាប់ ។ ទី២ ធ្វើឱ្យខូចមិត្តភាពកម្ពុជា-វៀតណាម ។

សេចក្តីដូចបានជំរាបជូនខាងលើ សហគមន៍ខ្មែរកម្ពុជាក្រោម ស្នើសុំសម្តេច មេត្តាជួយធ្វើអន្តរាគមន៍ទៅរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម:

១- សុំឱ្យក្រុមគ្រួសារ និងអង្គការសិទ្ធិមនុស្សនានា បានចូលជួបព្រះតេជគុណទឹម សាខននៅមន្ទីរឃុំឃាំងនៃប្រទេសវៀតណាម ដើម្បីមើលអំពីសុខភាពរបស់ព្រះអង្គ ។

២- អន្តរាគមន៍តាមគ្រប់មធ្យោបាយការទូត ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់សញ្ជាតិ ដើម្បីនាំយកព្រះតេជគុណទឹម សាខនត្រឡប់មកកម្ពុជាវិញ ។

៣- ស៊ើបអង្កេតរកឱ្យឃើញអ្នកណាដែលបានចាប់បញ្ជូនព្រះអង្គទៅឱ្យអាជ្ញាធរវៀតណាម ។

អាស្រ័យហេតុនេះ សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាជួយចាត់វិធានការធ្វើអន្តរាគមន៍ឱ្យបានប្រញាប់បំផុត ដែលអាចធ្វើទៅបាន ដោយសេចក្តីអនុគ្រោះ ។

សូមសម្តេច មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៧

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

អតីតសមាជិកព្រឹទ្ធសភា

ចម្លងផ្ញើ ដើម្បីជូន

- ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ
- ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា
- ឯកសារ-កាលប្បវត្ត


ភូមិគ្រឹះលេខ៩៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ

ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៩ ៥៨១, ១២ ៨៥១ ៩៩១ / ៩០ ៨៨ ៨២.

អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.or